ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានពន្ធដារ
លេខ......១៧២៦......អពដ

រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ មិនា ឆ្នាំ២០១៥

# សេចក្តីជូនដំណឹង
## ស្តីពីការស្នើសុំអាជ្ញាប័ណ្ណភ្នាក់ងារសេវាកម្មពន្ធដារ

អនុលោមតាមច្បាប់ស្តីពីសារពើពន្ធ និងប្រកាសលេខ ៤៥៥ សហវ.ប្រក ចុះថ្ងៃទី១២ ខែមេសា ឆ្នាំ២០១៣ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីភ្នាក់ងារសេវាកម្មពន្ធដារ អគ្គនាយកដ្ឋានពន្ធដារមានកិត្តិយស សូមជម្រាបជូនដំណឹងដល់ លោក-លោកស្រី ឬក្រុមហ៊ុនដែលមានលក្ខណៈវិនិច្ឆ័យជាភ្នាក់ងារសេវាកម្មពន្ធដារទាំងអស់ ដែលមានបំណងប្រកបអាជីវកម្មជាភ្នាក់ងារសេវាកម្មពន្ធដារ អាចដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណភ្នាក់ងារសេវាកម្មពន្ធដារ តាមនីតិវិធីដូចខាងក្រោម÷

### ក. ការស្នើសុំអាជ្ញាប័ណ្ណរបស់រូបវន្តបុគ្គល

លោក-លោកស្រី ជារូបវន្តបុគ្គលដែលមានលក្ខណៈវិនិច្ឆ័យជាភ្នាក់ងារសេវាកម្មពន្ធដារទាំងអស់ ត្រូវធ្វើការស្នើសុំអាជ្ញាប័ណ្ណភ្នាក់ងារសេវាកម្មពន្ធដារ នៅអគ្គនាយកដ្ឋានពន្ធដារ ដោយភ្ជាប់មកជាមួយនូវ÷

១. ពាក្យស្នើសុំអាជ្ញាប័ណ្ណភ្នាក់ងារសេវាកម្មពន្ធដារ
២. អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែន និងឯកសារបញ្ជាក់អាសយដ្ឋានបច្ចុប្បន្នរបស់បុគ្គលស្នើសុំ
៣. វិញ្ញាបនប័ត្រភ្នាក់ងារសេវាកម្មពន្ធដារ (ចំពោះបេក្ខជនដែលបានប្រឡងជាប់ជាភ្នាក់ងារសេវាកម្មពន្ធដារ) ឬឯកសារបញ្ជាក់ជាសមាជិកវិទ្យាស្ថានគណនេយ្យករ និងសវនករជំនាញកម្ពុជា (ចំពោះគណនេយ្យករ និងសវនករជំនាញ) ឬលិខិតបញ្ជាក់ពីអតីតភាពការងារពីអគ្គនាយកដ្ឋានពន្ធដារ (ចំពោះអតីតមន្ត្រីពន្ធដារ)
៤. លិខិតបញ្ជាក់ទីតាំងដែលធ្វើសកម្មភាពភ្នាក់ងារសេវាកម្មពន្ធដារ
៥. ឯកសារបញ្ជាក់អំពីការចុះបញ្ជីជាអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស បង់ពន្ធប៉ាតង់ ឬបង់ពន្ធអាករផ្សេងៗ តាមច្បាប់ត្រឹមត្រូវ។

### ខ. ការស្នើសុំអាជ្ញាប័ណ្ណរបស់ក្រុមហ៊ុននីតិបុគ្គល ឬក្រុមអាជីវកម្ម

ក្រុមហ៊ុននីតិបុគ្គល ឬក្រុមអាជីវកម្ម ដែលមានលក្ខណៈវិនិច្ឆ័យជាភ្នាក់ងារសេវាកម្មពន្ធដារទាំងអស់ ត្រូវធ្វើការស្នើសុំអាជ្ញាប័ណ្ណភ្នាក់ងារសេវាកម្មពន្ធដារ នៅអគ្គនាយកដ្ឋានពន្ធដារ ដោយភ្ជាប់មកជាមួយនូវ÷

១. ពាក្យស្នើសុំអាជ្ញាប័ណ្ណភ្នាក់ងារសេវាកម្មពន្ធដារ
២. ឯកសារចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម
៣. វិញ្ញាបនប័ត្រភ្នាក់ងារសេវាកម្មពន្ធដារ ឬឯកសារបញ្ជាក់ជាសមាជិកវិទ្យាស្ថានគណនេយ្យករ និងសវនករជំនាញកម្ពុជា (KICPAA) ឬអាជ្ញាប័ណ្ណសេវាកម្មគណនេយ្យនិងសវនកម្ម ចេញដោយក្រសួង

Collection by VCAT Professional Consultant


អាគារកែងមហាវិថី សហព័ន្ធរុស្សី (១១០) និង ម៉ៅសេទុង (២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ (+855) 23 886 708 ទូរសារ: (+855) 23 886 700, Email: gdt@tax.gov.kh, Website: www.tax.gov.kh

សេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

៤. លិខិតបញ្ជាក់ទីតាំងដែលធ្វើសកម្មភាពភ្នាក់ងារសេវាកម្មពន្ធដារ

៥. ឯកសារបញ្ជាក់អំពីការចុះបញ្ជីជាអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស បង់ពន្ធប៉ាតង់ ឬបង់ពន្ធអាករផ្សេងៗ តាមច្បាប់ត្រឹមត្រូវ។

ក្នុងករណី លោក-លោកស្រី ឬក្រុមហ៊ុននីតិបុគ្គល ឬក្រុមអាជីវកម្មដែលប្រកបអាជីវកម្មជាភ្នាក់ងារសេវាកម្មពន្ធដារ ដោយគ្មានអាជ្ញាប័ណ្ណ ត្រូវចាត់ទុកថាប្រព្រឹត្តអំពើរំលងស្មុះដូចមានចែងក្នុងមាត្រា១២៨ និងត្រូវទទួលរងការផ្តន្ទាទោសតាមមាត្រា ១៣៦ នៃច្បាប់ស្តីពីសារពើពន្ធ។

សូមទាក់ទងការិយាល័យសេវាអ្នកជាប់ពន្ធនិងចុះបញ្ជី នៃនាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំដោយផ្ទាល់ចំពោះពាក្យស្នើសុំអាជ្ញាប័ណ្ណ ការដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណ និងព័ត៌មានផ្សេងៗ ឬតាមរយៈទូរស័ព្ទ ០២៣ ៨៨៦ ៧១២ ឬទាញយក (Download) ពាក្យស្នើសុំអាជ្ញាប័ណ្ណ តាមរយៈគេហទំព័ររបស់អគ្គនាយកដ្ឋានពន្ធដារ www.tax.gov.kh។

អគ្គនាយកដ្ឋានពន្ធដារ សង្ឃឹមនិងជឿជាក់ថា លោក-លោកស្រី និងក្រុមហ៊ុនដែលមានលក្ខណៈវិនិច្ឆ័យជាភ្នាក់ងារសេវាកម្មពន្ធដារទាំងអស់ ពិតជាយកចិត្តទុកដាក់អញ្ជើញមកស្នើសុំអាជ្ញាប័ណ្ណជាភ្នាក់ងារសេវាកម្មពន្ធ ចាប់ពីថ្ងៃជូនដំណឹងនេះតទៅ។

**ប្រតិភូរាជរដ្ឋាភិបាល**

**ទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ**

**គង់ វិបុល**